ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
=======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
=======

# មាតុភូមិនិវត្តន៍របស់ពលករ-ពលការិនីខ្មែរ៣នាក់ ពីប្រទេសម៉ាឡេស៊ី

------------

ស្ថានឯកអគ្គរាជទូត**កម្ពុជា**ប្រចាំប្រទេស**ម៉ាឡេស៊ី** បានរៀបចំមាតុភូមិនិវត្តន៍របស់ពលករ-ពលការិនីខ្មែរ ចំនួន**៣នាក់** ដូចខាងក្រោម៖

(១) ពលការិនី **ស.ផ.ល** អាយុ២៩ឆ្នាំ មកពីខេត្តកំពង់ធំ បានទៅប្រទេសម៉ាឡេស៊ី តាមរយៈមេខ្យល់ នៅថ្ងៃទី១៩ កញ្ញា ឆ្នាំ២០១៦ ដោយធ្វើដំណើរតាមរថយន្តកាត់តាមប្រទេសថៃ និងធ្វើការជាអ្នកបោសសំអាត។ ដោយធ្វើការលំបាក នាងបានស្នើស្ថានទូតនៅថ្ងៃទី២៨ ខែតុលា ជួយឲ្យបានត្រឡប់មកកម្ពុជាវិញ។

(២) ពលការិនី **ឡ.គ.យ** អាយុ៤១ឆ្នាំ មកពីខេត្តត្បូងឃ្មុំ បានទៅម៉ាឡេស៊ី តាមរយៈមេខ្យល់ នៅថ្ងៃទី២៥ កញ្ញា ឆ្នាំ២០១៦ ហើយបានធ្វើការនៅរោងចក្រអារឈើ។ ដោយធ្វើការលំបាក ពលការិនីបានទៅស្ថានទូត នៅថ្ងៃទី២១ ខែវិច្ឆិកា ស្នើសុំស្ថានទូតជួយឲ្យបានត្រឡប់មកកម្ពុជាវិញ។

(៣) ពលករ **អ.ស.រ** អាយុ១៤ឆ្នាំ ជាកូនប្រុសរបស់ពលការិនី**ឡ.គ.យ** បានទៅម៉ាឡេស៊ីជាមួយម្តាយ នៅថ្ងៃទី២៥ កញ្ញា ឆ្នាំ២០១៦។

អ្នកទាំង៣ ត្រូវបាន**អង្គការចាប់ដៃ**នៅកម្ពុជា ឧបត្ថម្ភសំបុត្រយន្តហោះជូន ហើយនឹងមកដល់ព្រលានយន្តហោះអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី**០១ ខែធ្នូ ឆ្នាំ២០១៦** វេលាម៉ោង**៤:០០ រសៀល** តាមជើងយន្តហោះ AK534។ អំឡុងពេលរង់ចាំត្រឡប់មកកម្ពុជាវិញ ស្ថានទូតបានផ្តល់កន្លែងស្នាក់នៅ និងអាហារបរិភោគដល់អ្នកទាំង៣ផងដែរ៕

ភ្នំពេញ, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៦
**ជុំ សុន្ទរី**
**អ្នកនាំពាក្យ**
ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ